**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១០៧ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ឯកឧត្តម **ប្រាំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៤- | អនុប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន | សមាជិក |

| | |
|---|---|
| ៥- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៤- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥- ឯកឧត្តម **លេខ ទី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិកអចិន្ត្រៃយ៍ |
| ១៦- អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ១៧- អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៨- អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៩- អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ២០- អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ២១- ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត | សមាជិក |
| ២២- អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ២៣- អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| ២៤- អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង | សមាជិក |
| ២៥- អភិបាល នៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| ២៦- អភិបាល នៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| ២៧- អភិបាល នៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| ២៨- អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ២៩- អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៣០- អភិបាល នៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| ៣១- អភិបាល នៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ៣២- អភិបាល នៃគណៈអភិបាលខេត្តកែប | សមាជិក |

**ប្រការ ២.-**

គណៈកម្មការខាងលើនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាខេត្តកម្ពុជា ដែលជាប់ព្រំដែនជាមួយប្រទេសវៀតណាម ដើម្បីត្រៀមរៀបចំខ្លឹមសារកិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែននេះឱ្យបានគ្រប់ជ្រុងជ្រោយ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ពិភាក្សា និងសម្របសម្រួលជាមួយក្រុមការងារវៀតណាម ដើម្បីរៀបចំខ្លឹមសារ និងកិច្ចការនានាឱ្យបានសមស្របសម្រាប់កិច្ចប្រជុំលើកទី៩ នេះ
- រៀបចំគម្រោងថវិកាចំណាយនានាពាក់ព័ន្ធនឹងកិច្ចប្រជុំ
- ធានាឱ្យដំណើរការនៃកិច្ចប្រជុំប្រព្រឹត្តទៅមានភាពរលូន និងទទួលបានលទ្ធផលល្អប្រសើរ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រមុខរាជរដ្ឋាភិបាល។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានក្រុមការងារអន្តរក្រសួងត្រូវសុំយោបល់ដឹកនាំផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារអន្តរក្រសួង។

**ប្រការ ៤.-**

ក្រុមការងារអន្តរក្រសួងអាចមានគណៈកម្មការមួយចំនួនជាជំនួយការ ដែលកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រធានក្រុមការងារអន្តរក្រសួងអាចស្នើសុំមន្ត្រីនៃទីស្តីការក្រសួងមហាផ្ទៃ ឬមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងក្រុមការងារអន្តរក្រសួង ឱ្យជួយការងារតាមការចាំបាច់ តាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីនៃក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធទាំងនោះ។

**ប្រការ ៥.-**

ក្នុងការសម្របសម្រួលរៀបចំខ្លឹមសារនៃកិច្ចប្រជុំ ក្រុមការងារអន្តរក្រសួងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យចូលរួមតាមការចាំបាច់។

**ប្រការ ៦.-**

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងមហាផ្ទៃក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៧.-**

ក្រុមការងារអន្តរក្រសួងបញ្ចប់កិច្ចការរបស់ខ្លួន បន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាលរួចរាល់ជាស្ថាពរ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អភិបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ